# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្តីសង្ខេបនៃការពិភាក្សាពិគ្រោះយោបល់ជាមួយវិស័យឯកជន*

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

<u>អ្នកចូលរួម៖</u> មានតំណាងចំនួន ១០រូប មកពីផ្នែកឯកជនដែលធ្វើការនៅក្នុងប្រទេសកម្ពុជា។

<u>សេចក្តីផ្តើម៖</u> ធនាគារពិភពលោកបើកកិច្ចពិគ្រោះយោបល់នេះដោយធ្វើការរៀបរាប់សង្ខេបពីអំពីបរិបទរបស់ប្រទេស និងអាទិភាពនានាក្នុងកិច្ចការអភិវឌ្ឍន៍ ដូចត្រូវបានរកឃើញតាមរយៈការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) ព្រមទាំងសំណើវិស័យត្រូវផ្តោតយកចិត្តទុកដាក់សម្រាប់ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ដែលសម្របខ្លួនតាមអាទិភាពរបស់យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា។ បណ្តាវិស័យត្រូវផ្តោតយកចិត្តទុកដាក់ក្នុងក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) រួមមាន៖ ១) លើកកម្ពស់ប្រសិទ្ធផលរបស់រដ្ឋ និងជំរុញការអភិវឌ្ឍវិស័យឯកជន, ២) ជំរុញការអភិវឌ្ឍមនុស្ស, ៣) កែលម្អវិស័យកសិកម្ម និងពង្រឹងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិឱ្យកាន់តែប្រសើរ និងមូលបទអន្តរវិស័យស្តីពីការពង្រឹងអភិបាលកិច្ច ស្ថាប័ន និងការចូលពាក់ព័ន្ធរបស់ពលរដ្ឋ។ បន្ថែមលើមាគ៌ាដែលត្រូវបានត្រួសត្រាយដោយការវិនិច្ឆ័យស្ថានភាពប្រទេសមានលក្ខណៈជាប្រព័ន្ធ (SCD) និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា មានគោលដៅពិចារណាមើលអំពីឧត្តមភាពប្រៀបធៀបនៃវិស័យគម្រោងអនុវត្តនានារបស់ក្រុមធនាគារពិភពលោក។ បន្ទាប់មក អ្នកចូលរួមបានធ្វើការពិភាក្សាលើសំណួរដែលក្រុមការងារធនាគារពិភពលោកបានស្នើឡើង។

<u>បញ្ហាធំៗដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សាមាន៖</u> ការដឹកជញ្ជូន កសិកម្ម វិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍជំនាញ។

| **វិស័យដែលត្រូវបានលើកយកមកពិភាក្សា** | **ចំណុចគោលសំខាន់ៗដែលបានលើកឡើង** |
|---|---|
| **តើអ្វីខ្លះទៅជាបញ្ហា** | ***វិស័យហិរញ្ញវត្ថុ*** |

| | |
|---|---|
| **ប្រឈមនិងភាពចាំបាច់បន្ទាន់ជាងគេនៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា**? | ▪ អាចនឹងមានផលប៉ះពាល់អវិជ្ជមានខ្លះទៅលើផ្នែកឯកជន ប្រសិនបើសហភាពអឺរ៉ុបដកភាពអនុគ្រោះពាណិជ្ជកម្មក្រោមកិច្ចព្រមព្រៀង« គ្រប់មុខទំនិញទាំងអស់លើកលែងតែសព្វាវុធ» *(Everything But Arms)* ពីកម្ពុជា។<br>▪ ជាមួយកំណើនឥនទានខ្ពស់ ការផ្តល់កម្ចីនឹងបន្ថយល្បឿន ដោយសារតែការតម្រូវឱ្យមានការដាក់តម្កល់មូលធនបម្រុងបន្ថែម 1.25% ដែលកំណត់ដោយធនាគារជាតិ គិតចាប់តាំងពីខែមករា ឆ្នាំ២០១៩ ទៅ (តាមរយៈនេះ ការតម្កល់មូលធនបម្រុងនឹងឡើងដល់ទៅ 2.5% ក្នុងឆ្នាំ២០២០)។<br>▪ មកទល់ពេលនេះមិនទាន់មានទិន្នន័យ ឬ ស្ថិតិស្តីពីសហគ្រាសធន់តូចនិងមធ្យមមានលក្ខណៈឯកភាព និងរួមគ្នានៅមួយកន្លែងដែលមានភាពទុកចិត្តបានសម្រាប់យោងទេ។<br>▪ អំពីសេដ្ឋកិច្ចឌីជីថល ធនាគារជាតិកម្ពុជាមិនទទួលយកច្បាប់ចម្លងឯកសារពាក់ព័ន្ធជាលក្ខណៈទន់/ឌីជីថលទេ។ នាយកដ្ឋានពន្ធដារតម្រូវផ្នែកឯកជនឱ្យបង្ហាញច្បាប់ចម្លងជាលក្ខណៈក្រដាសនូវព័ត៌មានហិរញ្ញវត្ថុក្នុងបណ្ណាសារមានអាយុកាល១០ឆ្នាំ ដែលនេះជាការតម្រូវមួយដែលអ្នកផ្តល់កម្ចីមានការលំបាកក្នុងការបំពេញតាម។<br><br>***ការដឹកជញ្ជូន/ថាមពល***<br>▪ ថ្លៃចំណាយលើការដឹកជញ្ជូនខ្ពស់ ហើយបណ្តាញផ្លូវគមនាគមន៍ខ្វះតំណភ្ជាប់គ្នាពីមួយទៅមួយ<br>▪ ថ្លៃខ្ពស់របស់ថាមពលអគ្គិសនីនៅតែជាបញ្ហាប្រឈមមួយសម្រាប់ការធ្វើធុរកិច្ចនៅប្រទេសកម្ពុជា<br><br>***កសិកម្ម***<br>▪ វិស័យកសិកម្មនៅខ្វះការធ្វើយន្តូបនីយកម្ម ខ្វះកម្លាំងពលកម្ម ខ្វះការធ្វើពិពិធកម្មដំណា និងខ្វះតម្លៃបន្ថែម<br>▪ ផលិតផលកសិកម្មនៅខ្វះស្តង់ដាគុណភាព<br>▪ ខ្វះការស្រាវជ្រាវអំពីការកែលម្អផលិតភាពដំណាំនៅក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ និងដំឡូងមី។<br>▪ ជាទូទៅ កសិករទម្លាប់ធ្វើការដាំដំណាំតែមួយរដូវ (ជាពិសេសស្រូវ)។<br>▪ មានការបង់ខាតខ្ពស់នៅរដូវក្រោយប្រូតកាត់ ដោយសារតែការដឹកជញ្ជូននិងបណ្តាញគមនាគមន៍នៅមានការខ្វះខាតសម្រាប់អនុញ្ញាតឱ្យកសិករអាចដឹកជញ្ជូនផលិតផលរបស់ខ្លួនពីកសិដ្ឋានទៅកាន់ឃ្លាំង និងទីផ្សារ ប្រកបដោយប្រសិទ្ធភាព។<br>▪ មានការធ្វើការកត់សម្គាល់ថាមានភាពប្រសើរតិចតួចនៅក្នុងវិស័យកសិកម្ម ហើយកម្ពុជាចាំបាច់ត្រូវមានការគាំទ្របន្ថែមទៀតដល់ហេដ្ឋា |

| | |
|---|---|
| | រចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ និងលទ្ធភាពរកបានទីផ្សារសម្រាប់កសិផល។<br><br>***ជំនាញ***<br>▪ ប្រទេសកម្ពុជាមានវត្ថុធាតុដើមប៉ុន្តែខ្វះជំនាញដើម្បីផលិតចេញជាផលិតផលសម្រេច។ កម្មករ មានជំនាញគឺជាតម្រូវការចាំបាច់ដើម្បីបង្កើនផលិតភាព និងការធ្វើអន្តរកម្មទៅធ្វើការផលិតផលិតផលដែលមានគុណភាពខ្ពស់ ដូចជាគ្រឿងបរិក្ខារម៉ាស៊ីនត្រជាក់ ឬឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ជាដើម។ |
| **តើមានអ្វីខ្លះជាវិស័យអាទិភាពសម្រាប់ក្រុមធនាគារពិភពលោកបន្តជួយឧបត្ថម្ភនៅក្នុងអំឡុងពេល៥ឆ្នាំខាងមុខ? មានអ្វីខ្លះដែលក្រុមធនាគារពិភពលោកគួរបន្តសកម្មភាពជួយបន្ថែមទៀត ឬបន្ថយសកម្មភាពវិញ?** | • ធនាគារពិភពលោកបានជួយគាំទ្រដល់វិស័យដឹកជញ្ជូន ប៉ុន្តែធនាគារគួរតែធ្វើការបន្ថែមទៀតដើម្បីកាត់បន្ថយការចំណាយលើផ្នែកនេះ។ រដ្ឋាភិបាលទទួលស្គាល់ថាបញ្ហានេះជាឧបសគ្គចម្បងមួយ។<br>• ធនាគារពិភពលោកគួរតែជួយគាំទ្រដល់កសិករឱ្យរៀនប្រែក្លាយខ្លួនឯងទៅជាសហគ្រិនកសិ-ពាណិជ្ជករ។<br>• ការធ្វើពិពិធកម្មផលិតផលឱ្យជាដំណាំមានតម្លៃខ្ពស់គួរតែត្រូវបានបង្កើតឡើង សម្រាប់ដំណាំដូចជាម្រេច ស្វាយចន្ទី ផ្លែឈើនិ ងបន្លែជាដើម។<br>• កែលម្អប្រសិទ្ធផលនៃការកែច្នៃកសិផលតាមរយៈការបង្កើតមជ្ឈមណ្ឌលកែច្នៃកសិផល ការកំណត់តំបន់ដីកសិកម្ម និងការលើកទឹកចិត្តផ្នែកពន្ធ។<br>• លើកកម្ពស់កសិផលិតផលក្នុងស្រុក ទម្លាប់អនុវត្តកសិកម្មល្អ GAP និងការបង្កើតឡើងនូវយីហោកសិផល ជាដើម។<br>• រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍គួរតែខិតខំកែលម្អបណ្តាញភ្ជាប់គមនាគមន៍ឱ្យបានកាន់តែល្អឡើង ដូចជាផ្លូវ និងផ្លូវទឹក ជាដើម។<br>• ធ្វើឱ្យសុវត្ថិភាពអាហារ វិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យ និងលទ្ធភាពរកបានទីផ្សារ កាន់តែមានភាពប្រសើរថែមទៀត។<br>• ធ្វើឱ្យមានភាពប្រសើរឡើងនូវភាពជឿជាក់របស់វិនិយោគិន តាមរយៈការកែលម្អការអនុវត្តច្បាប់ ភាពអាចទស្សន៍ទាយបាន និងតម្លាភាព។<br>• លើកកម្ពស់ផ្នែកអាហារូបត្ថម្ភឱ្យល្អថែមទៀត។ |
| **តើមានអ្វីខ្លះដែលអាចជាបញ្ហា** | • រដ្ឋាភិបាលគួរតែពិគ្រោះយោបល់ជាមួយវិស័យឯកជន មុនពេលអនុម័តច្បាប់ណាមួយដែលនឹងជះផលប៉ះពាល់ដល់វិស័យឯកជន។<br>• គោលនយោបាយលើកលែងពន្ធគួរតែត្រូវបានពិនិត្យឡើងវិញ ហើយការដាក់កម្រិតចំនួនអប្បបរមា ០,៥លានដុល្លារសហរដ្ឋអាមេរិក |

| | |
|---|---|
| **ប្រឈមគួរឱ្យកត់សម្គាល់សម្រាប់ការអនុវត្ត ហើយថាតើបញ្ហាប្រឈមទាំងនោះអាចត្រូវបានកាត់បន្ថយដោយរបៀបណាខ្លះ?** | នឹងមិនទៅរួចទេសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម ដែលមានចំណូលត្រឹមពី ៣ ទៅ ៥លានដុល្លារនោះ។ |
| **អត្ថាធិប្បាយផ្សេងៗទៀត** | • ចំណាត់ថ្នាក់ដាក់ដោយធនាគារពិភពលោកស្តីពីគមនាគមន៍ដឹកជញ្ជូនគឺមានលេខ៨៥ ក្នុងចំណោម១៨០ប្រទេស។ ចំណាត់ថ្នាក់នេះគួរតែមានការកែលម្អឡើង ដោយសារថាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជាមានភាពប្រសើរជាងមុនដែរហើយ។<br>• ទំហំសំណាកសម្រាប់ធ្វើការស្ទាប់ស្ទង់កំណត់ចំណាត់ថ្នាក់ស្តីពីការធ្វើធុរកិច្ច (Doing Business Rankings) គួរត្រូវបានពង្រីកឱ្យទូលំទូលាយជាងនេះ ហើយគួរបង្កើនសំណួរបន្ថែមទៀតដែរនៅជុំវិញប្រធានបទនេះ។ |